# អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍
# Action for Research and Development

សមត្ថភាព គុណភាព តម្លាភាព
Capacity Quality Transparency

ផ្ទះលេខ ៩១F ផ្លូវ ២៦៥ សង្កាត់ ទឹកល្អក់ ៣
ខណ្ឌទួលគោក ក្រុងភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ០១៦ ៧៧៨ ៧០១
អ៊ីម៉ែល: ard.cabodia@yahoo.com
ard.info@yahoo.com
ប្រអប់សំបុត្រ: CCC ៣០៤

# ពត៌មានសំខាន់សំរាប់អ្នក
# Necessary News for You

## ព្រឹត្តិបត្រពត៌មានប្រចាំខែ
## Monthly Newsletter

ចែកជូនដោយឥតគិតថ្លៃ

### មាតិកាពត៌មាន

- គំរោងផ្សព្វផ្សាយ និងពង្រឹងសមត្ថភាព ជំហាន១ របស់អង្គការ ARD ..... 2
- ដំណឹងជ្រើសរើសបុគ្គលិក.............................................. 3
- ធ្យូងពូតផលិតពីកាកសំណល់កសិកម្មធ្វើបានជោគជ័យនៅខេត្តបាត់ដំបង..... 5
- ឆ្នេរសមុទ្រកំពុងរងការបំពុលបរិស្ថាន................................ 7
- ភាពអាម៉ាសរបស់មន្ត្រីកម្ពុជា តាមរយៈការធ្វើព្រងើយកន្តើយ............. 8
- ការធ្លាក់ចុះសីលធម៌សង្គមនៅក្នុងស្រទាប់យុវវ័យ....................... 10

# កម្មវិធីរបស់ ARD

## គំរោងផ្សព្វផ្សាយ និងពង្រឹងសមត្ថភាព ជំហាន១ របស់អង្គការ ARD

ដើម្បីរក្សានូវគោលជំហរ ទស្សនៈវិស័យដើមនៅក្នុងការបង្កើតអង្គការ ARD ក្រុមស្ថាបនិករបស់អង្គការ បានផ្តួចផ្តើមរៀបចំគំរោងមួយដែលមានឈ្មោះថាគំរោង **ផ្សព្វផ្សាយ និងពង្រឹងសមត្ថភាពជំហាន១** ក្នុងគោលបំណងពង្រឹង និងពង្រីកនូវការរួមចំណែកអោយបានសកម្ម នៅក្នុងការអភិវឌ្ឍន៍សង្គមជាតិទាំងផ្នែកសមត្ថភាព និងបច្ចេកទេសជំនាញដល់សិស្ស និស្សិត និងប្រជាកសិករនៅតំបន់ជនបទក្រីក្រ ។

គំរោងផ្សព្វផ្សាយ និងពង្រឹងសមត្ថភាពជំហាន១ រៀបចំឡើងសំរាប់ដំណើរការសាកល្បងក្នុងរយៈពេលចំនួន ៦ខែ គឺចាប់ពីខែតុលា ឆ្នាំ២០០៦ រហូតដល់ខែមីនា ឆ្នាំ២០០៧ ក្រោមការគាំទ្រថវិកាពីស្ថាបនិករបស់អង្គការ គាំទ្រផ្នែកស្មារតីដោយក្រុមប្រឹក្សាពិគ្រោះយោបល់ និងអនុវត្តដោយបុគ្គលិកស្ម័គ្រចិត្តរបស់អង្គការ **គំរោងនេះមានអ្នកទទួលផលពីរប្រភេទសំខាន់ គឺ :**

- **អ្នកទទួលផលផ្ទាល់ :** គឺមានសិស្ស និស្សិត បុគ្គលិកអង្គការ/រដ្ឋាភិបាល នៅក្នុងវគ្គបណ្តុះបណ្តាលជំនាញខ្លីសំរាប់ជាទុន នៅក្នុងការអភិវឌ្ឍន៍អាជីពរបស់ខ្លួន ដែលសរុបមានចំនួន ១០០នាក់ ។ ក្រៅពីនេះមានប្រជាកសិករ ដែលនឹងត្រូវចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងការធ្វើបង្ហាញ ស្តីពីការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ តាមគោលការណ៏ធម្មជាតិ ចំនួន ២០ គ្រួសារ ។

- **អ្នកទទួលផលប្រយោល :** គឺជាអ្នកទទួលផលសំខាន់ទី២របស់គំរោង តាមរយៈការទទួលបាននូវព្រឹត្តិបត្តពតិមាន និងសៀវភៅពីបណ្ណាល័យរបស់អង្គការ និងប្រជាកសិករដែលបានចូលរួមនៅក្នុងការធ្វើវេទិ-ការកសិករទាក់ទងនឹងការផ្សព្វផ្សាយពីការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ តាមគោលការណ៏ធម្មជាតិ ។ ក្នុងនោះ អ្នកទទួលបានព្រឹត្តិបត្តិពតិមានប្រចាំខែរបស់អង្គការ មានចំនួនសរុបចំនួន ៧០០ នាក់ (រួមទាំងនិស្សិត បុគ្គលិកអង្គការ/រដ្ឋា-ភិបាល) ។ អ្នកចូលអាន និងប្រើប្រាស់សៀវភៅនៅក្នុងបណ្ណាល័យ សរុបចំនួន ១០០នាក់ ។ ប្រជាកសិករដែលចូលរួម ក្នុងវេទិកាកសិករ សរុបចំនួន ៤០នាក់ ។

គំរោងផ្សព្វផ្សាយ និងពង្រឹងសមត្ថភាព ចែកចេញជា៤សមាសភាពសំខាន់គឺ :

**១. សមាសភាពអភិវឌ្ឍន៏ធនធានមនុស្ស :** សមាសភាពនេះ មានគោលបំណងផ្តល់នូវចំណេះដឹងបន្ថែមដល់និស្សិត បុគ្គលិកអង្គការ/រដ្ឋាភិបាលនានា ដើម្បីជាទុននៅក្នុងការរក រីអភិវឌ្ឍន៏ការងារនៅតាមបណ្តាអង្គការ ស្ថាប័នផ្សេងៗ ជាពិសេសផ្នែកអភិវឌ្ឍន៏សហគមន៏ ។ សរុបវគ្គបណ្តុះបណ្តាលដែលត្រូវរៀបចំឡើង មានចំនួន៦វគ្គ ដែលក្នុងនោះផ្តោតទៅលើប្រធានបទសំខាន់ចំនួន ៤ គឺ :

- ការងារអភិវឌ្ឍន៏សហគមន៏
- ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន
- ការត្រួតពិនិត្យ និងវាយតំលៃគំរោង
- កត្តាគន្លឹះសំរាប់អភិវឌ្ឍន៏ការងារអាជីព

សមាសភាពនេះ ក៏មានធ្វើការស្រាវជ្រាវអង្កេតចំនួនពីរ ស្តីពីការប្រើប្រាស់ថ្នាំពុលទៅលើដំណាំបន្លែ និងឥទ្ធិពលរបស់វា នៅក្នុងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម និងស្តីពីគីរិតជីវភាពរស់នៅរបស់ប្រជាកសិករ នៅក្នុងឃុំពេជ្រមុនី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

**២. សមាសភាពបោះពុម្ពផ្សាយ និង គេហទំព័រ :** គំរោងនឹងបោះពុម្ពព្រឹត្តិបត្តិពតិមានប្រចាំខែឈ្មោះថា ពតិមានសំខាន់សំរាប់អ្នក និងចាប់ផ្តើមផ្សព្វផ្សាយពីពតិមានផ្សេងៗ នៅលើគេហទំព័រខ្លួនផងដែរ ។

**៣. សមាសភាពកែលំអការចិញ្ចឹមមាន់ ជាលក្ខណៈគ្រួសារតាមគោលការណ៏ធម្មជាតិៈ** គំរោងមានរៀបចំការធ្វើបង្ហាញការចិញ្ចឹមមាន់ចំនួន ១០បង្ហាញ នៅក្រោយពីបានបណ្តុះបណ្តាលកសិករចំនួន២០នាក់រួច ។

**៤. សមាសភាពពង្រឹងសមត្ថភាពបុគ្គលិក :** បុគ្គលិកស្ម័គ្រចិត្តចំនួន ៨នាក់ នឹងត្រូវបានបណ្តុះបណ្តាលពង្រឹងសមត្ថភាពបន្ថែម ទាក់ទងនឹងការងារអនុវត្តគំរោង ការសរសេររបាយការណ៏ ការងារផ្សព្វផ្សាយ ការស្រាវជ្រាវ ។

**គិតរហូតមកទល់ពេលនេះ គំរោងបានចាប់ផ្តើមអនុវត្តរយៈពេល២ខែ ហើយដែលមានការចូលរួមសហការយ៉ាង ជិតស្និតពីសំណាក់អជ្ញាធរដែនដី ដែលក្នុងនោះមានថ្នាក់អភិបាលស្រុក ក្រុមប្រឹក្សាឃុំ អជ្ញាធរភូមិ និងប្រជាពលរដ្ឋនៅក្នុងទីតាំង គោលដៅផងដែរ ។ ពិនិត្យជារួមគំរោងនេះមានទំហំតូច និងរយៈពេលខ្លីពិតមែន ប៉ុន្តែ យ៉ាងហោចណាស់វានឹងបានចូលរួមចំណែកធ្វើអោយកាន់តែប្រសើរឡើងនៅក្នុងការអភិវឌ្ឍន៏សង្គមកម្ពុជាយើង ។**

# ទំព័រឱកាសសំរាប់អ្នក

## Brief Job News

# ដំណឹងជ្រើសរើសបុគ្គលិក

| | |
|---|---|
| KHANA | : Senior management/leadership |
| CSD | : Many Positions |
| ARD | : NREM Trainees |
| UNDP | : Senior Finance and Admin Advisor |
| ACF | : Legal Training Manager |
| WildAid | : Community Developers/Accountant |
| NIPH | : Project Coordinator/ Procurement Officer |
| World Vision | : Project Manager |
| Plan International | : Legal Expert |
| Youth For Peace | : Project Officer and Facilitators |
| Caritas Cambodia | : Project Manager |

**The Khmer HIV/AIDS NGO Alliance (KHANA)** is inviting applications from Cambodian nationals for the following vacancies based in Phnom Penh. Both of these jobs are **senior management/leadership** positions reporting directly to the Executive Director.
Interested candidates must submit a CV and a cover letter specifying the position applying for the Mr. Kim Rattana, management support Officer at KHANA Office. Only short-listed candidates will be notified. Vacancies are expected to be filled by end January 2007. Detailed job description for these positions is available at www.khana.org.kh
**Address :** # 33, Street 71, Tonle Bassac, Phnom Penh.
**Closing Date: 22 December 2006**

---

**The Center for Social Development ("CSD")** has been awarded a grant for three years from the International Development Research Center ("IDRC") via the Ministry of Commerce ("MOC") to conduct a pilot project entitled "i-REACH" in the field of information communication technology ("ICT") in Kep Municipality. The headquarters of the i-REACH Project is based at the district office of Domnak Chang Oeur (centrally located on national route 33) with 9 centers to spread across 11 villages. CSD is seeking qualified and experienced Khmer national to be based in Kep Municipality for following posts:

- Pilot Project Coordinator
- Research Coordinator
- Community Radio Coordinator
- Technical Staff
- Technical Assistant (10 available positions)
- Service Content Developer (3 positions)

Application, including Cover Letter, CV and the names of three referees, should reach CSD by ***Friday, 29 December 2006***. Applications may be send to No.19, St.57, Boeung Keng Kang I, Chamkarmorn, Phnom Penh, or emailed to info@csdcambodia.org.
For further inquires, please telephone 023 364 735 and ask for Mr. Ly Much.
**Closing Date: 29 December 2006**

**Action for Research and Development (ARD)** is seeking the **20 Trainees** to attend **the training course on Natural Resource and Environment Management (NREM Training)**
**After completing this course NREM Trainee will get:**

- Well understanding regarding Natural Resource and Environment Management in Cambodia including community preservation establishment process
- Get knowledge regarding Facilitation skill, PRA, Planning and Reporting and can apply all this knowledge for working with NGOs.
- NRETs will work closely with other volunteer teams of ARD in order to get fruitful according to the plan.

**Requirement:**

- All students are studying at University focused on social science, agriculture, community development or other relevant academic. We are strongly encouraged for student who just graduated from University.
- Willingness to work as a team and interested with Natural Resource and Environment Preservation and Rural Development work

Interested candidates who wishing to get experiences in the purpose of working with NGOs are invited to send **Letter of interest and CV with current photo** to ARD **not later than 22 December 2006** through office No. 51F, Street 265. Sangkat Teok Laak III, Khan Tuol Kork, Phnom Penh or CCC Box #304 or E-mail: ard.cambodia@yahoo.com.
**The short list of candidates will post in front of ARD office on 27 December 2006.** For more information please contact through phone number 012 292 830.

---

**The Office of the United Nations Development Program** is seeking to fill the following vacancy as **Senior Finance and Admin Advisor** for its project based in **National Committee for Management of Decentralization and Deconcentration Secretariat (NCDDS)**. More details are on the website http://www.un.org.kh/undp/. In your application letter and CV, please address the job specifications, and attach a completed UN Personal History Form (P11). Send the application by email to applications.kh@undp.org, by identifying the post title in the subject line. Only applications that address the selection criteria will be considered. This vacancy is open to international applicants. UNDP will contact referees directly. Applications received after the closing date will not be considered. Only short-listed candidates will receive acknowledgement. *Women are especially encouraged to apply.*
**Address :** # 53, Pasteur (St. 51), Phnom Penh
**Fax :**023 216 257
**Email :** registry.kh@undp.org
**Closing Date: 08 December 2006**

# ទំព័រឱកាសសំរាប់អ្នក

# ដំណឹងជ្រើសរើសបុគ្គលិក

## Brief Job News Continue....

**The Arbitration Council Foundation (ACF)**, an independent and non-political organization established with initial funding and assistance from the ILO to provide support to the Arbitration Council of the Kingdom of Cambodia which aids in the resolution of labor disputes, seeks a talented and experienced Cambodian national for the position of **Legal Training Manager**, based in Phnom Penh.
The detailed job description and additional information for the above position can be obtained upon request via **e-mail Jobs@arbitrationcouncil.org**.
A covering letter with a short statement addressing the above requirement and a CV with 3 referees should be sent via the above e-mail address or by mail to the Arbitration Council at Room 331, Building A, Phnom Penh Center, Corner of Preah Sihanouk and Sothearos Blvd, Sangkat Tonle Bassac, Phnom Penh.
**Closing Date: 11 December 2006**

---

**Wild Aid** is an international non-profit organization dedicated to protecting wildlife by assisting governments strengthens protected areas, increase public awareness to reduce demand, and provide alternative livelihoods for poachers and land encroachers through sustainable agriculture assistance. To assist on a USAID-supported Community Agriculture Development Project (CADP), Wild Aid requires:
**Community Developers (3 positions):** *Kandoul Commune, Botum Sakor District, Koh Kong Province*
**Accountant/Logistics (1 position):** *Koh Kong province*
Send application in English with comprehensive CV and recent photograph to Wild Aid. *Only short-listed candidates will be contacted for interview.*
**Address :** Villa 109, Street 99, Psar Doeum Tkhov
**Email :** myrna@online.com.kh
**Closing Date: 15 December 2006**

---

**The National Institute of Public Health (NIPH)** of the Ministry of Health is requires the services of additional contractual to perform specific functions within its program. NIPH is currently recruiting a Cambodian of position of **Project Coordinator** (duration 8 months) **and Procurement Officer** (duration: 8 months).
Interested persons should apply in writing, with a copy of an up-to-date CV, to: Administration Office, National Institute of Public Health. Applications should mark clearly 'title of the position you are applying for' on the enveloped and send to about address **by or before 17:00 on Thursday, *December 14, 2006*.**
**Address :** Mo. 2, Kim Yi Sung Blvd, Khan Toul Kork, Phnom Penh.
**Closing Date: 14 December 2006**

**World Vision Cambodia (WVC),** a non-profit Christian Humanitarian Organization, committed to working with the poor and vulnerable, is seeking a qualified Cambodian to fill a vacant position of **Project Manager for HIV/AIDS Prevention and Care for Mothers and Infants (HAPCAMI) for HIV/AIDS Program** based in Phnom Penh.
Interested applicants should obtain an official **WVC's application form** and submit with CV and cover letter to HR Department, World Vision Cambodia or email to **cam_recruitment@wvi.org**.
**Address :** #20, St. 71, Sangkat Tonle Basak, Khan Chamkamorn, Phnom Penh, PO Box: 479
**Phone :** 023 216 052
**Closing Date: 15 December 2006**

---

**Plan International** is seeking qualified International and Cambodian national to fill the position **Legal Expert** (National Consultant, 6 months duration, 1st January to 31st June 2007).
Interested candidates are requested to submit their CV together with a cover letter and at least three referees to Human Resource Department, Plan International Cambodia.Email: HR.Cambodia@plan-international.org
**Address :** #99-100, Street Preah Sothearos, Sangkat Tonle Bassac, Khan Chamcamorn, Phnom Penh
**Closing Date: 15 December 2006**

---

**Youth For Peace** is a Cambodian NGO are looking for one **Project Officer** and **Facilitators** for our new program: Youth for Justice and Reconciliation.
Please send CV and Cover letter to YFP Administrative Office with attention to Executive Director. Women are encouraged to apply. All CVs are not returned.
**Address :** # 109 AB, Street 261/192, Sangkat ToeukLaak III, Khan Tuolkork, Phnom Penh
**Phone :** 023 881 346
**Fax :**023 881 346
**Closing Date: 15 December 2006**

---

**Caritas Cambodia** is an international Non-Governmental Organization. In Siem Reap, Caritas Cambodia has developed a large Community Health Program and is currently seeking a qualified applicant for the position of **Project Manager for the Community Health Program and Community Health Nurse** .This position is based in Svay Leu District and Kvav commune in Sothnikum Operational District.
Interested candidates are requested to submit a letter and a comprehensive CV to Caritas Cambodia office.
**Caritas Cambodia**
**Address :** Street Lauk Taneuy, Wat Bo Village, Salakamroeuk Commune, Siem Reap
**Closing Date: 29 December 2006**

# កសិកម្ម និងការអភិវឌ្ឍន៍

## ផ្សូងពួតផលិតពីកាកសំណល់កសិកម្មធ្វើបានជោគជ័យនៅខេត្តបាត់ដំបង

នៅព្រះរាជាណាចក្រកម្ពុជាយើង វិស័យកសិកម្ម គឺជាអាទិភាពចំបងនៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ដែលមានប្រជាពលរដ្ឋសរុបជាង៨០ភាគរយជាកសិករ រីឯអាកាសធាតុ សណ្ឋានដីទៀតសោធក៏ផ្តល់អំណោយទានដល់ការងារផលិតកម្មកសិកម្មបានយ៉ាងល្អ ។ ផលិតផលកសិកម្មដូចជាស្រូវ ពោត សណ្តែក ល្ង ការចិញ្ចឹមសត្វ ។ល។ សុទ្ធសឹងតែជាប្រភពដែលមិនអាចអត់បានសំរាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទូទាំងប្រទេស ។ មិនត្រឹមតែប៉ុណ្ណោះកាកសំណល់ពីផលិតផលកសិកម្មទាំងនេះ ប្រសិនបើចេះច្នៃប្រឌិត អាចបន្តប្រើប្រាស់វាសំរាប់ជាប្រយោជន៏យ៉ាងច្រើនទៀតនៅក្នុងការបង្កើនប្រាក់ចំណូល បង្កើនទិន្នផល ជាពិសេសបានចូលរួមកាត់បន្ថយនូវការប្រើប្រាស់ធនធានធម្មជាតិខ្ជះខ្ជាយថែមទៀត ។ ដើម្បីជាការចូលរួមចំណែកកាត់បន្ថយនូវការចំណាយច្រើនទៅលើការប្រើប្រាស់អុស ធ្យូង ក៏ដូចជាប្រើប្រាស់ដោយសន្សំសំចៃទៅលើធនធានធម្មជាតិរបស់យើង ពតិមានសំខាន់សំរាប់អ្នក នៅលេខនេះ សូមនាំមកបច្ចេកទេសសាមញ្ញថ្មីដែលអនុវត្តបានជោគជ័យសំរាប់ការផលិតធ្យូងដោយមិនបានកាប់ដើមឈើមកធ្វើជាវត្ថុធាតុដើម ។ ការផលិតធ្យូងពួតនេះត្រូវបានអនុវត្តនៅខេត្តបាត់ដំបង ហើយដែលយើងសូមដកស្រង់អត្ថបទនេះ ចេញពីកាសែតកោះសន្តិភាព ចេញផ្សាយថ្ងៃសុក្រទី១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ដូចខាងក្រោម :

ដោយប្រើឧបករណ៏ម៉ាស៊ីន សមត្ថភាពផលិតធ្យូតពួតកើនឡើងពី២០ ទៅ១២០គីឡូក្រាមក្នុងមួយថ្ងៃ ហើយគុណភាពវាក៏ល្អប្រសើរឡើងដែរ។ គេបន្ថែមបរិមាណដីឥដ្ឋ ១ភាគរយទៀតដើម្បីបង្កើនកំរិតកំដៅ។ ការប្រើប្រាស់ម្សៅដំឡូងដែលជាជាតិស្អិត(អាចពូតជាប់) ត្រូវកាត់បន្ថយ២ភាគរយ ពីព្រោះការពូតដោយកំលាំងម៉ាស៊ីនត្រូវការម្សៅដំឡូងតិចសំរាប់ការពូតជាប់ល្អ។ គេមិនចាំបាច់រែងកំទេចធ្យូងឱ្យម៉ដ្ឋ(ដូចម្សៅ)ដូចមុនទៀតទេ ពីព្រោះកំទេចធ្យូងគ្រើម ក៏អាចពូតហាប់បានដែរ។ សមាមាត្រ នៃការលាយកំទេចធ្យូង ដីឥដ្ឋ និងម្សៅដំឡូង នាពេលបច្ចុប្បន្ននេះគឺ ១០:៤:៤ ដែលពីមុនគឺ ១០០:៣:៦:៣ (សមាមាត្រកំទេចធ្យូង ដីឥដ្ឋ ម្សៅ និងជ័រទឹក)។

**ការរកទីផ្សាលក់ធ្យូងបានជោគជ័យ :**

រយៈពេលបួនប្រាំខែក្រោយពីការធ្វើតេស្តទីផ្សារ នៅខែកុម្ភៈ ២០០៦ អ្នកប្រើប្រាស់ ដែលធ្លាប់បានសាកល្បងប្រើធ្យូងពួតរបស់ ASDD បានចាប់ផ្តើមទិញវិញ។ ទោះជាយ៉ាងនេះក្តី ក៏មានការចែកឱ្យអ្នកផ្សេងទៀត ដោយមិនគិតថ្លៃដែរ រហូតដល់ខែមិនា ទើបASDD អាចលក់ធ្យូងបានពេញថ្លៃ គឺ ៣០០រៀល/គ.ក្រ (១ដុល្លារ= ៤១០០រៀល)គិតទាំងថ្លៃដឹកជញ្ជូន។ ក្នុងពេលនោះតំលៃធ្យូងធម្មតា ដែលផលិតដោយឡដុតធ្យូងតាមបែបប្រពៃណី គឺ ៥០០រៀល/គ.ក្រ។ បច្ចុប្បន្ន ASDD មានអតិថិជនជាវចំនួន២០នាក់ ដែលម្នាក់ៗត្រូវការធ្យូងពី៥០ ទៅ៣០០គីឡូក្រាម រៀងរាល់២សប្តាហ៏ម្តង។ ក្នុងចំណោមអតិថិជនទាំងនោះ មាន១០នាក់ប្រើជាលក្ខណៈគ្រួសារ ៥នាក់លក់រាយ និង៥នាក់ប្រើចំអិនអាហារលក់។ អតិថិជនទាំងនោះជាប្រជាជនរស់នៅទីប្រជុំជន នៃផ្សារថ្មគោល និងបាត់ដំបង ។

បច្ចុប្បន្ននេះ ការផ្គត់ផ្គង់ធ្យូងពួតមិនទាន់គ្រប់គ្រាន់តាមតំរូវការនោះទេ។ ប៉ុន្តែខែថ្មីៗនេះ ធ្យូងធម្មតាក្នុងស្រុក ឡើងថ្លៃដល់ ៦០០រៀល/គ.ក្រ ហើយ ASDD កំពុងតែពិចារណាលើការដំឡើងថ្លៃធ្យូងរបស់ខ្លួនដល់៤០០រៀល/គ.ក្រ។

**សមត្ថភាពផលិតនាពេលបច្ចុប្បន្ន :**

នៅសិប្បកម្ម ASDD មានជួលមនុស្សចំនួន៥នាក់សំរាប់បំរើការងារ ៤នាក់ជាកម្មករ (ស្រ្តី៣នាក់ជាអ្នកលាយល្បាយ និងហាលធ្យូង និងបុរសម្នាក់ទៀតជាអ្នកបញ្ជាម៉ាស៊ីន) និងម្នាក់ជាបុគ្គលិកទីផ្សារ និងលក់។ ពួកគេបំរើការ៥ថ្ងៃ/សប្តាហ៏ ចាប់ពីថ្ងៃចន្ទ័រហូតដល់ថ្ងៃសុក្រ ។

ក្នុងមួយជើង ASDD ដឹក២.៥ តោនកំទេចធ្យូង ដែលមានសំណើម៤០ ភាគរយចេញពីរោងចក្រអគ្គីសនី ដោយ

# កសិកម្ម និងការអភិវឌ្ឍន៍

ចំណាយលើថ្លៃដឹកជញ្ជូនអស់ ១០០.០០០ រៀល ។ បន្ទាប់មកធ្យូងត្រូវហាលថ្ងៃសំងួត រយៈពេល ២-៣ថ្ងៃមុនពេលកិន ។

ពីប្រភពដើមរហូតបានជាកំទេចធ្យូងសំរេច( បាត់បង់នៅពេលសំងួត និង កិន) គេទទួលបានទិន្នផល៥០ភាគរយនៃទំងន់នៃប្រភពដើម។ ជារៀងរាល់ថ្ងៃរោងចក្រអគ្គីសនីនេះ បញ្ចេញកាកសំណល់សើមចំនួន៧០០គីឡូក្រាម ដែលអាចកែច្នៃកំទេចធ្យូងស្ងួត ៣៥០គីឡូក្រាម។ ក្នុងកំទេចធ្យូងស្ងួត១០០គីឡូក្រាម អាចផលិតចេញជាធ្យូងពូតសំរេចបាន ១១៥ គីឡូក្រាម។ ជាមធ្យមក្នុងមួយថ្ងៃសិប្បកម្មរបស់ASDD ផលិតធ្យូងពូតបាន១៧០ គីឡូក្រាម ។

**ផែនការពង្រីកផលិតកម្ម :**

ដោយសារការផ្គត់ផ្គង់មិនទាន់តំរូវការ ASDDមានបំណងវិនិយោគលើឧបករណ៍ផ្សេងទៀត ដើម្បីបង្កើតផលិតធ្យូងឱ្យបានដល់ទៅ ៣០០គ.ក្រ/ថ្ងៃ ។ ឧបករណ៍ទាំងនោះ រួមទាំងត្បាល់ដែលអាចកិនធ្យូង និងឧបករណ៍ដែលអាចសំងួតធ្យូង ។

ASDD មានការព្រួយបារម្ភរណ៍មួយថា ប្រភពផ្គត់ផ្គង់កំទេចធ្យូងដោយឥតគិតថ្លៃនោះនឹងលែងមានទៀតហើយដោយសារតែម្ចាស់រោងចក្រ ចាប់អារម្មណ៍បង្កើតអាជីវកម្មផ្ទាល់ខ្លួនដែរ ។ ទោះជាយ៉ាងនេះក្តី បើតាមអ្នកជំនាញ GERES បានលើកឡើងថា វានៅមានជំរើសសំរាប់ ASDD ក្នុងការប្រើប្រាស់ស្លលពោតដោយផ្ទាល់ ដោយសារវាមានតំលៃថោក ហើយកំដៅដែលកើតនៅក្នុងអំឡុងពេលដុតស្លលពោតឱ្យក្លាយជាធ្យូងអាចប្រើសំរាប់សំងួតធ្យូងពូតបានដែរ ។ក្នុងករណីនេះ ដើម្បីអាចចំណេញបាន វាទាមទារឱ្យមានការរៀបចំប្រពន្ធ័សង្វាក់ផលិតកម្មដ៏មានប្រសិទ្ធភាព និងការគ្រប់គ្រងបានល្អ ។

**ការរួមចំណែកនៃធ្យូងពូតចំពោះបញ្ហាភាពក្រីក្រ និងបរិស្ថាន :**

បច្ចុប្បន្ននេះASDD អាចរកប្រាក់ចំណេញបាន១១០.០០០រៀល/ខែ ហើយបានផ្តល់ការងារដល់មនុស្សចំនួន ៥នាក់ ដែលម្នាក់ៗទទួលបានប្រាក់ខែ ១៥០.០០០ រៀល/ខែ។ នេះមានន័យថា វាបានបង្កើតការងារ និងប្រាក់ចំណូលបន្ថែមដល់ប្រជាជនក្រីក្រ ។

**មួយវិញទៀតផលិតកម្មធ្យូងពូតអាចជួយគ្រប់គ្រងការបោះបង់កាកសំណល់ដែលអាចកាត់បន្ថយការប៉ះពាល់ដល់ផ្នែកបរិស្ថាន ដែលបង្ករឡើងដោយការបំពុលពីសំរាម ហើយក៏ផ្តល់នូវប្រភពថាមពលប្រកបដោយចីរភាពដល់មនុស្សផងដែរ។ ធ្យូងពូត អាចប្រើជំនួសធ្យូងអុសធម្មតានៅក្នុងស្រុកបាន ហើយជាការរួមចំនែកក្នុងការកាត់បន្ថយការកាប់ព្រៃឈើធម្មតា ដើម្បី យកអុសធ្វើធ្យូងសំរាប់ប្រើប្រាស់ ។**

បើទោះបីជាអាជីវកម្មនេះ មិនទាន់ផ្តល់នូវផលចំណេញខាងផ្នែកសេដ្ឋកិច្ច ក្នុងកំរិតខ្ពស់នៅឡើយ ប៉ុន្តែវាបានផ្តល់នូវផលប្រយោជន៍ជាច្រើនផ្នែកសង្គម និងបរិស្ថាន

ពតិមានសំខាន់សំរាប់អ្នក សូមធ្វើការបំភ្លឺដល់អ្នកអានទាំងអស់អោយបានជ្រាបផងដែរថា ការលើកឡើងនូវបច្ចេក-ទេសធ្វើធ្យូងពូតដោយអង្គការ ASDD នេះមិនមែនមានន័យជាការជួយឃោសនាដល់អង្គការនេះឡើយ ប៉ុន្តែវាជាបច្ចេកទេសមួយដែលគួរទទួលយកបាន និងប្រើប្រាស់ផលិតផលពីបច្ចេកទេសនេះ ដោយសារវាបានកាត់បន្ថយចំណាយក្នុងការទិញធ្យូងធម្មតា ក៏ដូចជាការចូលរួមថែរក្សាធនធានធម្មជាតិ និងបរិស្ថានអោយមាននិរន្តរភាពផងដែរ ។ ហើយតាមរយៈបច្ចេកទេសនេះបងប្អូនប្រជាកសិករអាចយកទៅធ្វើជាទុនបង្កើតអោយមានការផលិតធ្យូងដែលអាចច្នៃប្រឌិតសំរាប់ប្រើប្រាស់ជាលក្ខណៈគ្រួសារបានទៀតផងនៅពេលទៅអនាគត ។

អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ដែលមានទស្សនៈវិស័យចូលរួមកាត់បន្ថយភាពក្រីក្រ តាមរយៈការអប់រំ ផ្សព្វផ្សាយពីបច្ចេកទេសកសិកម្មសមស្រប និងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានដែលមាននិរន្តរភាព សូមគាំទ្រយ៉ាងពេញទំហឹង នូវការនាំអោយមានការបង្កើតថ្មី ហើយដែលចូលរួមប្រកបដោយប្រសិទ្ធិភាព នៅក្នុងការជួយសំរួលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ នៅតំបន់ជនបទ ។

# ទំព័រធនធានធម្មជាតិ និងបរិស្ថាន

## ឆ្នេរសមុទ្ររងការបំពុលបរិស្ថាន

កាលពីខែមុន ពតិមានសំខាន់សំរាប់អ្នកបានលើកយកអំពីសារៈសំខាន់នៃដើមត្នោតដែលជាធនធានធម្មជាតិដ៏មានតំលៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាការពញ្ញាក់អារម្មណ៏ដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូបយល់ពីសារៈប្រយោជន៏ និងចូលរួមថែរក្សាការពារកុំអោយបាត់បង់ ។ នៅលេខនេះ យើងសូមលើកឡើងពីសារៈប្រយោជន៏របស់ធនធានធម្មជាតិផ្នែកទេសចរណ៏ ហើយដែលប្រសិនបើប្រជា-ពលរដ្ឋយើងមិនថែរក្សាអោយបានស្អាតទេនោះវានឹងធ្វើអោយប៉ះពាល់ដល់បរិស្ថានទេវិញ ដែលជាការបាត់បង់នូវប្រយោជន៏របស់វា ។

ធនធានធម្មជាតិដែលពតិមានសំរាប់អ្នកលើកឡើងមកនេះ គឺធនធានឆ្នេរសមុទ្រដែលលាតសន្ធឹងនៅក្នុងខេត្តក្រុងចំនួន៤របស់ព្រះរាជាណាចក្រកម្ពុជាយើង គឺខេត្តកោះកុង កំពត ក្រុងព្រះសីហនុ និងក្រុងកែប ។ ក្រៅពីការផ្តល់ប្រយោជន៏ជាធនធានមច្ឆជាតិដ៏សំបូរបែប រ៉ែបាតសមុទ្រ វត្ថុធាតុដើមផលិតអំបិល តំបន់ឆ្នេរសមុទ្រព្រះរាជាណាចក្រកម្ពុជាបានផ្តល់នូវឆ្នេរខ្សាច់ និងសំរស់ធម្មជាតិដ៏ស្រស់ត្រកាលដែលទាក់ទាញបាននូវភ្ញៀវទេសចរជាតិ អន្តរជាតិដ៏ពេញនិយម ដែលជំរុញអោយមានការបង្កើតជាមុខរបរដល់ប្រជាពលរដ្ឋមូលដ្ឋានសំរាប់បង្កើនប្រាក់ចំណូលគ្រួសារ ដូចជាការបង្កើតភោជនីយដ្ឋានកែច្នៃវត្ថុអនុស្សាវរីយ៏ពីធនធានសមុទ្រ ផ្ទះសំណាក់ សណ្ឋាគារ មគ្គុទេសទេសចរណ៏ជាដើម ។ ផលប្រយោជន៏ទាំងអស់នេះ នឹងទទួលបានយ៉ាវមានប្រសិទ្ធិភាព ប្រសិនបើប្រជាពលរដ្ឋយើង រួមជាមួយអជ្ញាធរដែនដីសមត្ថកិច្ចពាក់ព័ន្ធនានាចេះរួមគ្នាថែរក្សាបរិស្ថាន ដើម្បីអោយបរិយាកាសនៅតំបន់ឆ្នេរនេះពោរពេញទៅដោយផាសុខភាព។ ផ្ទុយទៅវិញប្រសិនបើតំបន់ឆ្នេរទាំងនេះមានទេសភាពស្រស់ត្រកាលល្អយ៉ាងណាក៏ដោយ ប៉ុន្តែប្រសិនបើតំបន់ទាំងនេះមានបរិស្ថានកខ្វក់ ពោរពេញទៅដោយសំរាម កាកសំណល់ផ្សេងៗ ពាសពេញផ្ទៃឆ្នេរ រឺទឹកសមុទ្រ ។ ជាក់ស្តែងជាការព្រួយបារម្ភណាស់ ដែលតាមរយៈកាសែតរស្មីកម្ពុជា ចេញផ្សាយលេខ៤១២៩ ថ្ងៃសុក្រទី១០ខែវិច្ឆិកា ឆ្នាំ២០០៦ បានអោយដឹងថា តំបន់ឆ្នេរខ្សាច់សមុទ្រក្រុងព្រះសីហនុសព្វថ្ងៃនេះ កំពុងទទួលរងនូវការបំពុលបរិស្ថានកាន់តែធ្ងន់ធ្ងរឡើងៗ ដែលបណ្តាលមកពីការស្នាក់នៅរបស់មនុស្សការប្រកបអាជីវកម្មលក់ដូរ មានចំនួនច្រើន និងការប្រើសប្រាស់តំបន់ឆ្នេរខ្សាច់គ្មានអនាម័យ ។

អ្នកក្រុងភ្នំពេញម្នាក់ ដែលសុំមិនបញ្ចេញឈ្មោះបាននិយាយថា ឆ្នេរខ្សាច់ក្រុងព្រះសីហនុកំពុងមានការប្រែពណ៌ ពីសទៅក្រហម ហើយការប្រែប្រួលខុសពីធម្មជាតិបែបនេះ ក៏កំពុងធ្វើអោយមានផលប៉ះពាល់លើវិស័យទេសចរណ៏នៅតំបន់មាត់សមុទ្រដ៏សំខាន់របស់ប្រទេសកម្ពុជាយើង ។

ប្រភពដដែលបាននិយាយរិះគន់ទៀតថា : វិស័យទេសចរណ៏មាត់សមុទ្ររបស់ក្រុងព្រះសីហនុគ្មានការអភិរក្សអ្វីដែលគួរអោយកត់សំគាល់សោះឡើយក្នុងកំឡុងពេលជាង២០ឆ្នាំកន្លងមកនេះគឺមានតែការរំលោភបំពានដណ្តើមកាន់កាប់ធ្វើកម្មសិទ្ធ និងការស្នាក់នៅប្រកបអាជីវកម្មលក់ដូរបែបអនាធិបតេយ្យ គ្មានអនាម័យកាន់តែច្រើនឡើងៗតែប៉ុណ្ណោះរីឯអាជ្ញាធរ និងសមត្ថកិច្ចជំនាញពាក់ពន្ធគិតតែពីចាត់តាំងកំលាំងរែអង្គាសប្រាក់ ចែកគ្នា ហើយមិនដែលគិតដល់ពីផលប៉ះពាល់អ្វីទាំងអស់ ។

នៅពេលដែលមានបញ្ហាផ្នែកបរិស្ថាននៅតំបន់ឆ្នេរនេះ ពតិមានសំខាន់សំរាប់អ្នកមានការសោកស្តាយជាពន់ពេកព្រោះវាជាមុខមាត់របស់ប្រទេសជាតិ ជាពិសេសវាបាននាំមកនូវប្រាក់ចំណូលយ៉ាងច្រើនសំរាប់គ្រួសារប្រជាពលរដ្ឋ ក៏ដូចជាប្រទេសជាតិ ដែលគួរតែគ្រប់សមត្ថកិច្ចពាក់ព័ន្ធទាំងអស់ រួមជាមួយអជ្ញាធរដែនដីជួយគ្នាអប់រំប្រជាពលរដ្ឋ និងមានវិធានការជាក់ស្តែងដើម្បីការពារអោយមានបរិស្ថានស្អាត ប៉ុន្តែផ្ទុយទៅវិញបែរជាសមត្ថកិច្ចដែលពាក់ព័ន្ធឆ្លើយដាក់គ្នាទៅវិញទៅមកមិនរួមចំណែកទទួលខុសត្រូវលើបញ្ហាដែលកើតឡើងនេះឡើយ ។ **ពតិមានសំខាន់សំរាប់អ្នក សូមអំពាវនាវដល់គ្រប់ស្ថាប័នប្រជាពលរដ្ឋទាំងអស់ ប្រកាន់យកនូវគំនិតស្រលាញ់ធម្មជាតិ បរិស្ថានស្អាត ដើម្បីជាប្រយោជន៏សំរាប់យើងទាំងអស់គ្នា ។**

# ជីវិត និងសង្គម

## ភាពអាម៉ាស់របស់មន្ត្រីកម្ពុជា តាមរយៈការធ្វើព្រងើយកន្តើយនៅក្នុងពេលប្រជុំកិច្ចការផ្សេងៗ ពិភាក្សាគំនិតកំពូលនានា នៅក្នុង និងក្រៅប្រទេស

វាពិតជាផ្តល់បាននូវការសង្ឃឹមជឿជាក់ទៅដល់មន្ត្រីជាន់ខ្ពស់នៅក្នុងការចូលរួមដឹកនាំប្រទេសជាតិ នៅពេលដែលប្រជាពលរដ្ឋបានដឹង លឺ និងឃើញជាក់ស្តែងថាមន្ត្រីទាំងនោះមានការយកចិត្តទុកដាក់នៅក្នុងរាល់ការដោះស្រាយបញ្ហានានាដែលជាទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងមានសកម្មភាពរស់រវើក ផ្តល់ជាមតិយោបល់អនុសាសន៍នៅក្នុងពេលប្រជុំកំពូលក៏រិតជាតិ អន្តរជាតិ ដើម្បីចូលរួមចំណែកកសាងជាយុទ្ធសាស្រ្តមួយសំរាប់ដឹកនាំប្រទេស ។ ប៉ុន្តែផ្ទុយទៅវិញប្រសិនបើមន្ត្រីទាំងនោះបង្ហាញនូវភាពព្រងើយកន្តើយ មិនរវីរវល់ដល់ការផ្តល់ជាមតិ យោបល់ក្នុងគោលដៅសំរេចបាននូវដំណោះស្រាយ រឺយុទ្ធសាស្រ្តទេនោះ វានឹងធ្វើអោយប្រជាពលរដ្ឋដែលជាម្ចាស់ប្រទេសអស់សង្ឃឹម បាក់ទឹកចិត្ត និងគ្មានជំនឿថាមានការរីកចំរើនសំរាប់ប្រទេសរបស់ខ្លួននោះឡើយ ។ មិនតែប៉ុណ្ណោះវាថែមទាំងបានធ្វើអោយអាប់អោនដល់កិត្តយស កេរ្តិ៍ឈ្មោះរបស់ប្រទេសជាតិទៀតផង តាមរយៈការចាក់ផ្សាយពីសកម្មភាពពិតក្នុងកំឡុងពេលប្រជុំរបស់មន្ត្រីទាំងនោះ តាមទូរទស្សន៍ ។

ដើម្បីជាការបង្ហាញអោយឃើញជាក់ស្តែងអំពីសកម្មភាពព្រងើយកន្តើយនៅក្នុងពេលប្រជុំពិភាក្សារបស់មន្ត្រីកម្ពុជាកន្លងមក សារពតិមានសំខាន់សំរាប់អ្នកលេខនេះ សូមលើកឡើងនូវរឿងរ៉ាវជាក់ស្តែង ដែលតែងតែកើតមានឡើងនៅក្នុងពេលប្រជុំរដ្ឋសភាកន្លងមក តាមរយៈការចាក់ផ្សាយរបស់ទូរទស្សន៍ជាតិកម្ពុជា ដែលយើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មានសេចក្តីរីករាយ និងមានមោទនភាពជាអតិបរមាចំពោះសមាជិក សមាជិការដ្ឋសភាដ៏ឧត្តុងឧត្តមភាគច្រើន បានយកចិត្តទុកដាក់ផ្តល់មតិយោបល់ និងពិភាក្សាយ៉ាងផុសផុល មុននឹងឈានទៅដល់ការអនុម័តច្បាប់សំរាប់ប្រើប្រាស់ទូទាំងប្រទេស ។ ប៉ុន្តែទន្ទឹមនឹងនេះប្រជាពលរដ្ឋក៏សង្កេតឃើញថាមានសមាជិក សមាជិការបស់រដ្ឋសភាមួយចំនួនតូច មិនដែលបានបញ្ចេញមតិ យោបល់ពិភាក្សាទៅលើអត្ថបទច្បាប់ ដែលរដ្ឋសភាបានលើកយកមកដើម្បីធ្វើការសំរេចអនុម័តនោះឡើយ មិនតែប៉ុណ្ណោះសមាជិកខ្លះបានអានកាសែត និងគួរអោយឈឺចាប់ជាងនេះនោះ គឺប្រជាពលរដ្ឋមើលឃើញមានមន្ត្រីមួយចំនួនតូចទៀត បានបិទភ្នែករយៈពេលយូរគួរសម ដែលមើលទៅឃើញ ហាក់ដូចជាកំពុងងងុយ និងនឿយហត់យ៉ាងខ្លាំងពីការងារថ្ងៃមុនបន្ទាប់នេះ ។

មិនថាតែសកម្មភាពរបស់មន្ត្រីនៅក្នុងប្រទេសប៉ុណ្ណោះទេ ដែលបង្ហាញនូវកាយវិការព្រងើយកន្តើយបែបនេះនោះ ប៉ុន្តែមន្ត្រីការទូតដែលជាតំណាងព្រះរាជាណាចក្រកម្ពុជាទាំងមូលប្រចាំនៅបរទេសក៏មានសកម្មភាពប្រហាក់ប្រហែលគ្នានេះដែរ ដែលកាសែតកោះសន្តិភាព ឆ្នាំទី ៣៩ លេខ ៥៨៦៦ ចេញផ្សាយ ថ្ងៃសុក្រទី ២០ ខែតុលា ឆ្នាំ២០០៦ បានសរសេរថាមានអ្នកការទូតម្នាក់នៅក្នុងក្រុមប្រតិភូរអចិន្ត្រៃយ៏កម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ(UN) ដែលមិនត្រូវបានស្គាល់ឈ្មោះ **បានដេកលក់នៅឯកិច្ចប្រជុំក្រុមន្ត្រីសន្តិសុខនៃអង្គការ សហប្រជាជាតិ (UN security council) ឬ (UNSC) នៅទីក្រុងញូយ៉ក សហរដ្ឋអាមេរិក កាលពីថ្ងៃទី ១៧ តុលា ឆ្នាំ២០០៦**កន្លងមក នៅក្នុងកិច្ចប្រជុំក្រុមមន្ត្រីសន្តិសុខ នៃអង្គការសហប្រជាជាតិដែលកំពុងតែពិចារណាស្ទង់មតិដើម្បីត្រៀមបោះឆ្នោតជ្រើសរើសសមាជិកថ្មី ។ ដែរនៅក្នុងការពិចារណានោះដែរ សហរដ្ឋអាមេរិកបានគាំទ្រ ដល់ប្រទេសហ្កាតេម៉ាឡា ដែលនឹងប្រកួតប្រជែងដើម្បីដណ្តើមសំលេងគាំទ្រជាមួយប្រទេសវ៉េណេហ្ស៊ុយអេឡា ដើម្បីចូលជាសមាជិកថ្មីរបស់ UNSC ដោយសារលោកប្រធានាធិបតី

# ជីវិត និងសង្គម

ហ៊ូហ្គោឆាវេស របស់វ៉េណេហ្ស៊ុយអេឡា គឺជាគូរបដិបក្សរបស់លោកប្រធានាធិបតី ចចដាប់បិលយូប៊ូសនៃសហរដ្ឋអាមេរិក។ សំរាប់ការគាំទ្ររបស់សហរដ្ឋអាមេរិកបាន ធ្វើអោយសម្ព័ន្ធមិត្តរួមទាំងកម្ពុជាផងនោះ បានស្របតាមនិងធ្វើអោយប្រទេសហ្គាតេ-ម៉ាឡា មានសំលេងនាំមុខនៅទីបំផុត។

ទាក់ទិនទៅនឹងកិច្ចប្រជុំដ៏សំខាន់នោះដែរ អ្វីដែលធ្វើអោយភាគីជាច្រើនមានការចាប់អារម្មណ៍នោះ គឺអ្នកការទូតម្នាក់បានដេកលក់នៅក្នុងកិច្ចប្រជុំ។ ជាការពិតណាស់ការដែលអ្នកការទូតដេកលក់នៅក្នុងកិច្ចប្រជុំដ៏សំខាន់នេះ ចាត់ទុកថាជារឿងធម្មតាបន្ទាប់ពីមានការនឿយហត់នៅក្នុងការពិចារណាលើរបៀបវារៈសំខាន់ផ្សេងៗ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយមិនគប្បីអោយកើតមានករណីបែបនេះឡើយ។

ក.ក.ន រូបភាពនេះត្រូវបានផ្សព្វផ្សាយដោយAFP ប្រចាំ UN ហើយត្រូវបានផ្សាយបន្តផ្ទាល់ដោយ Website manager online កាលពីថ្ងៃ ១៧ តុលា ឆ្នាំ២០០៦ លើកញ្ចក់ Internet ។

ពតិមានសំខាន់សំរាប់អ្នក បានពិចារណា វិភាគហើយវិភាគទៀត អំពីតួនាទីរបស់សមាជិករដ្ឋសភា ដែលយើងហៅថាតំណាងរាស្ត្រនេះ ក៏ដូចជាតួនាទីដ៏ឧត្តុង្គឧត្តមរបស់មន្ត្រីការទូត គឺសុទ្ធតែជាតំណាងដ៏ថ្លៃថ្នូររបស់ប្រជាពលរដ្ឋ របស់ប្រទេសជាតិទាំងមូល ហេតុនេះពតិមានសំខាន់សំរាប់អ្នក ក៏ដូចជាប្រជាពលរដ្ឋផ្សេងទៀតដែរ ចង់ឃើញ ចង់ដឹង និងចង់លឺថា ឧត្តមមន្ត្រីទាំងអស់ ដែលជាអ្នកតំណាងប្រជាពលរដ្ឋ តំណាងប្រទេសជាតិ បានបំពេញភារកិច្ចជូនប្រជាពលរដ្ឋ ប្រទេសជាតិប្រកដោយឧត្តមគតិ មនសិការ និងការយកចិត្តទុកដាក់ខ្ពស់ ។

**ដើម្បីជាកិត្តិយស កេរ្តិ៍ឈ្មោះ និងមុខមាត់របស់ព្រះរាជាណាចក្រកម្ពុជា ពតិមានសំខាន់សំរាប់អ្នក សូមធ្វើការសំណូមពរដ៏ទទូចដល់មន្ត្រីទាំងអស់ដែលកំពុងបំពេញភារកិច្ចជូនជាតិ ទាំងមន្ត្រីតូច មន្ត្រីធំ ឧត្តមមន្ត្រី តំណាងរាស្ត្រ និងអ្នកការទូត មេត្តាយកចិត្តទុកដាក់បំរើជាតិ បំរើប្រជាពលរដ្ឋ អោយសមតាមអ្វីដែលប្រជាពលរដ្ឋ និងប្រទេសជាតិ បានលើកតម្កើង និងប្រគល់តួនាទីជូន ។**

ពតិមានសំខាន់សំរាប់អ្នក សូមសំដែងនូវការអបអរសាទរយ៉ាងក្លាំងខ្លាជាមួយនឹងប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី ដែលបានថ្លែងក្នុងឱកាសចុះពិនិត្យមើលដំណើរការសាងសង់អគាររដ្ឋសភាថ្មី ដែលស្ថិតនៅក្បែរវិមានកាស៊ីណូដ៏ខ្ពស់ស្កឹមស្កៃនាពេលថ្មីៗនេះថា សម្តេចគ្មានផែនការដើម្បីបង្កើននូវចំនួនសមាជិក សមាជិការដ្ឋសភាបន្ថែមទៀតទេសំរាប់នៅអណត្តិទី៤ និងអណត្តិក្រោយៗទៀត ពីព្រោះសម្តេចយល់ឃើញថាសមាជិករដ្ឋសភាចំនួន ១២៣ រូបនេះ គឺល្មមគ្រប់គ្រាន់សំរាប់បំពេញការងារបានហើយ ។ មិនត្រឹមប៉ុណ្ណោះ សម្តេចបានអំពាវនាវផងដែរ សូមអោយរដ្ឋសភាប្រឹងប្រែងអោយក្លាំងខ្លាថែមទៀតនៅក្នុងការបំពេញកាតព្វកិច្ចជូនប្រជារាស្ត្រ និងប្រទេសជាតិ ជាពិសេសគួរបង្កើនការពិភាក្សាអនុម័តច្បាប់ថែមទៀត មិនគួរប្រជុំតែមួយពេលព្រឹកឡើយ ពីព្រោះរដ្ឋសភាពនៅជំពាក់ច្បាប់រាជរដ្ឋាភិបាលដែលបានបញ្ជូនមកច្រើនណាស់ ។

ជាមួយគ្នានេះ ពតិមានសំខាន់សំរាប់អ្នកសូមផ្តល់ជាសំណូមពរដល់សម្តេចនាយករដ្ឋមន្ត្រី រឺតស្សូរជនដែលនឹងឈ្នះឆ្នោតក្លាយជានាយករដ្ឋមន្ត្រីនៅអណត្តិក្រោយ សូមមេត្តាពិចារណាកាត់បន្ថយនូវចំនួនសមាជិករាជរដ្ឋាភិបាល និងគណៈអភិបាលខេត្ត ដែលមានច្រើនលើសលប់ក្នុងអណត្តិទី៣នេះ អោយមកនៅចំនួនតិចសមរម្យនឹងទំហំការងារ បំរើប្រជារាស្ត្រ ដែលមាននៅក្នុងទឹកដីតូចច្រលឹងនេះ ដោយហេតុ ពតិមានសំខាន់សំរាប់អ្នក យល់ឃើញថាការបង្កើនចំនួនសមាជិករាជរដ្ឋាភិបាលដ៏ច្រើនលើសលប់នេះ ពិតជាមិនមែនឆ្លើយតប ទៅនឹងតំរូវការជាក់ស្តែងឡើយ តែជាការសំរុះសំរួលផ្ទៃកនយោបាយ ទៅវិញប៉ុណ្ណោះ ។ **បន្ថែមពីលើនេះ ដើម្បីធានានូវប្រសិទ្ធិភាព និងគុណភាពការងារដ៏ថ្លៃថ្លា ស័ក្តសមជាស្ថាប័នកំពូល របស់ព្រះរាជាណាចក្រកម្ពុជា ពតិមានសំខាន់សំរាប់អ្នក សូមអំពាវនាវដល់គ្រប់គណបក្សទាំងអស់ មេត្តាសំរាំងយកតែតស្សូរជន ដែលមានសមត្ថភាពពិតប្រាកដ និងសកម្មការងារ ដើម្បីឈរឈ្មោះជាតំណាងរាស្ត្រ ។**

# ទំព័រចុងក្រោយសំរាប់អ្នក

## ការធ្លាក់ចុះនូវសីលធម៌សង្គមក្នុងស្រទាប់យុវវ័យ

បើយើងក្រលេកមើលក្នុងសង្គមខ្មែរសព្វថ្ងៃ ឃើញថាសីលធម៌ សុជីវធម៌ និងគុណធម៌មានការធ្លាក់ចុះយ៉ាងខ្លាំង ជាពិសេសនៅក្នុងស្រទាប់យុវវ័យ ។អំពើអប្បាយមុខ និងអសីលធម៌ជាច្រើន ត្រូវបានប្រព្រឹត្តិឡើងដោយយុវវ័យរបស់យើង មានដូចជាការសេពគ្រឿងញៀន ក្រុមបងធំ អំពើចាប់រំលោភសេពសន្ថវៈ ល្បែងស៊ីសង ជាដើម ។ល។

សកម្មភាពទាំងអស់ខាងលើនេះ កើតមានឡើងជាញឹកញាប់នៅគ្រប់ខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជារបស់យើង ហើយដែលមិនមែនតែពតិមានសំរាប់អ្នកទេដែលបានដឹង និងលឺអំពីសកម្មភាពដ៏គួរអោយព្រួយបារម្ភនេះ ។ **ជាក់ស្តែងនៅចុងខែវិច្ឆិកានេះ ក្នុងក្រុងព្រះសីហនុមានការភ្ញាក់ផ្អើលយ៉ាងកក្រើកទីក្រុង រួមជាមួយនឹងការព្រួយបារម្ភយ៉ាងខ្លាំង ទាក់ទងនឹងអនាគតកូនចៅយុវវ័យរបស់ប្រជាពលរដ្ឋនោះគឺរូបភាព បង្ហាញពីសកម្មភាពរួមសិចដ៏រោលរាលរបស់យុវជន និងយុវតីសិស្សសាលាដ៏ក្មេងខ្ចីមួយគូ នៅក្នុងបន្ទប់សណ្ឋាគារមួយ ដែលរូបភាពនេះបានចែកចាយចំលងតាមទូរស័ព្ទដៃពាសពេញក្រុង ។**

តាមរយៈរូបភាពសិចនេះ បានបង្កអោយមានការបារម្ភ និងរន្ធត់ពីសំណាក់មហាជនពិសេសមាតាបិតា រឺអាណាព្យាបាលសិស្ស ដែលមានបុត្រធីតារបស់ខ្លួនស្ថិតក្នុងវ័យដូចគ្នានេះ គឺខ្លាចពួកគេធ្លាក់ទៅក្នុងល្បែងស្នេហ៍ដ៏ ឆ្កួតលីលា ដែលសង្គមស្អប់ខ្ពើម ហើយដែលបុគ្គលផ្ទាល់ និងក្រុមគ្រួសារនឹងអាប់អោនកិត្តិយសកេរ្តិ៍ឈ្មោះ មិនតែប៉ុណ្ណោះអាចធ្វើអោយខូចអនាគតដល់យុវវ័យ ដែលជាអនាគតរបស់ប្រទេសជាតិទៀតផង ។ **នៅក្នុងករណីនេះ ទោះបីជាសកម្មភាពនៃការរួមសិចបែបអាសអាភាសនេះ មានការព្រមព្រៀងពីភាគីទាំងពីរក្តី មិនគួរណាយុវជន ជាពិសេសយុវតីដែលស្ថិតនៅការសិក្សា មិនគួរយកខ្លួនទៅប្រលែងលេងនឹងល្បែងស្នេហាដ៏រោលរាលទាំងវ័យក្មេងមិនទាន់គ្រប់ការយ៉ាងនេះទេ ដែលទីបំផុតត្រូវមិត្តប្រុសទុរយសរបស់ខ្លួន យកមករៀបជាឆាកសំដែង ថតរូបផ្សព្វផ្សាយជាវីដេអូចែកចាយគ្នាមើលយ៉ាងអយុត្តិធម៌បំផុត ។**

ភស្តុតាងមួយទៀតដែលបង្ហាញអោយឃើញនូវការមិនយកចិត្តទុកដាក់របស់យុវវ័យនៅក្នុងការសិក្សា ហើយដែលនឹងឈានទៅរកការប្រព្រឹត្តអំពើអនាចារផងដែរនោះ គឺកាលពីថ្ងៃទី២៩ ខែវិច្ឆិកានេះ **អជ្ញាធរមានសមត្ថកិច្ចក្រុងភ្នំពេញបានចុះធ្វើប្រត្តិបត្តិការ ប្រឆាំងនឹងការនាំចូលច្រៀងការ៉ាអូខេយ៉ាងពពាក់ពពូនរបស់ក្រុមសិស្សប្រុសស្រីដោយការគេចពីសាលារៀន។ នៅក្នុងយុទ្ធនាការនេះប៉ូលីសបានឃាត់ខ្លួនក្រុមសិស្សវង្វេងសាលា ចំនួន ១០០ នាក់ ជាមួយនឹងម៉ូតូចំនួន៥៥គ្រឿង ដើម្បីធ្វើការអប់រំណែនាំ និងបានអោយអាណាព្យាបាលធានាយកទៅអប់រំបន្ថែម ។** ជាការសោកស្តាយណាស់ដែលយើងឃើញនូវក្រុមសិស្សទាំងនេះនាំគ្នាគេចសាលាមិនចូលរៀន ហើយនាំគ្នាមកច្រៀងការ៉ាអូខេទាំងហ្វូងដោយមិនគិតអនាគតរបស់ខ្លួន ហើយវាកាន់តែអនិច្ចាទៀតនោះគឺ **អាណាព្យាបាលរបស់សិស្សទាំងនេះ ភាគច្រើនមិនបានដឹងទេថា កូនៗរបស់ខ្លួនមិនចូលរៀនដូចដែលបានស្លៀកពាក់ជាឯកសណ្ឋានសិស្សចេញពីផ្ទះមកនោះផងទេ ប៉ុន្តែបែរជាកូនៗរបស់គាត់បែរជាទៅត្រេកត្រអាលសប្បាយយ៉ាងភ្លើតភ្លើន នៅក្នុងបន្ទប់ការ៉ាអូខេនៅក្នុងម៉ោងសិក្សាទៅវិញ ។**

តាមរយៈសកម្មភាពរបស់អជ្ញាធរមានសមត្ថកិច្ច អជ្ញាធរមូលដ្ឋានដែលបានធ្វើយុទ្ធនាការដ៏ល្អទាំងនេះ ពតិមានសំខាន់សំរាប់អ្នក ក៏ដូចជាប្រជាពលរដ្ឋទូទៅដែរ សូមសំដែងនូវការស្វាគមន៍ និងអបអរសាទរយ៉ាងកក់ក្តៅនូវការចាត់វិធានការដ៏មានប្រសិទ្ធិភាពបែបនេះ ហើយសូមអំពាវនាវអោយបន្តនូវស្នាដៃដ៏គួរអោយកោតសរសើរនេះទៅទៀត សំដៅរួមចំណែកពង្រឹងសីលធម៌ សុជីវធម៌ និងសន្តិសុខសង្គមអោយកាន់តែមានភាពប្រសើរឡើង ។ **ជាមួយគ្នានេះពតិមានសំខាន់សំរាប់អ្នក សូមផ្តល់អនុសាសន៍ ដល់យុវជន យុវតីដែលស្ថិតនៅក្នុងវ័យសិក្សា បង្វែរអារម្មណ៍យកចិត្តទុកដាក់អោយបានខ្លាំងខ្លាលើការសិក្សារបស់ខ្លួនកុំបែកឆ្វេង ប្រព្រឹត្តិអំពើពាលាអាវ៉ាសែដែលសង្គមមិនអោយតំលៃ ជាប្រយោជន៍អនាគតដ៏រុងរឿងរបស់ខ្លួន គ្រួសារខ្លួន និងប្រទេសខ្លួន។**

**សូមផ្ញើរមតិរបស់អ្នកមកកាន់យើងខ្ញុំដើម្បីចុះផ្សាយ**

E-mail: ard.info@yahoo.com